# សុន្ទរកថារបស់**ឯកឧត្តម គូម៉ាម៉ារូ យូជិ**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីសម្ពោធក្លឹបហ្វឹកហាត់សម្រាប់ក្បាច់គុនយុទ្ធសិល្ប៍ជប៉ុន
២៤ មិនា ២០១៤

**សូមគោរព ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា!**
**សូមគោរព លោក ឡាច ច័ន្ទសុវណ្ណ ប្រធានខេមរៈសហព័ន្ធការ៉ាតេ-ដូ!**
**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចូលរួមក្នុងពិធីសម្ពោធក្លឹបហ្វឹកហាត់សម្រាប់ក្បាច់គុនយុទ្ធសិល្ប៍ជប៉ុន។ ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមាន និងការគាំទ្ររបស់ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ ខ្ញុំក៏សូមសម្តែងនូវការពេញចិត្តយ៉ាងខ្លាំងចំពោះលោក ឡាច ច័ន្ទសុវណ្ណ ប្រធានខេមរៈសហព័ន្ធការ៉ាតេ-ដូ និង អស់លោក-អ្នក ទាំងអស់ដែលបានខិតខំប្រឹងប្រែងដើម្បីបញ្ចប់គម្រោងសាងសង់ក្លឹបនេះប្រកបដោយជោគជ័យ។

ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការប្រកួតកីឡាអូឡាំពិកនៅទីក្រុងតូក្យូឆ្នាំ២០២០ រដ្ឋាភិបាលជប៉ុនបានផ្តួចផ្តើមគំនិតថ្មី ក្នុងការធ្វើកិច្ចសហប្រតិបត្តិការផ្នែកកីឡា ជាមួយប្រទេសនៅជុំវិញពិភពលោកដែលគម្រោងនៃគំនិតផ្តួចផ្តើមថ្មីនេះមានឈ្មោះថា "កីឡាសម្រាប់ថ្ងៃស្អែក"។ សម្រាប់គម្រោងគំនិតផ្តួចផ្តើមថ្មីនេះ ប្រទេសជប៉ុនមានបំណងឧបត្ថម្ភគាំទ្រដល់ប្រទេសដទៃទៀត ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធកីឡា និងបំពាក់សម្ភារៈកីឡាជាដើមក្នុងគោលបំណងលើកស្ទួយការយល់ដឹងអំពីតម្លៃនៃកីឡានៅជុំវិញពិភពលោក។ ខ្ញុំជឿជាក់ថាគម្រោងសាងសង់ក្លឹបហ្វឹកហាត់សម្រាប់ក្បាច់គុនយុទ្ធសិល្ប៍ជប៉ុន និងបំពាក់សម្ភារៈដែលចាំបាច់សម្រាប់ការប្រកួត និងការហ្វឹកហាត់ប្រចាំថ្ងៃគឺធ្វើឡើងស្របទៅនឹងគោលបំណងនៃរដ្ឋាភិបាលជប៉ុន។

ខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំងដោយបានកត់សម្គាល់ឃើញថាក្បាច់គុនយុទ្ធសិល្ប៍ជប៉ុនដែលមានដូចជាការ៉ាតេ-ដូ និងយូ-ដូ កាន់តែពេញនិយមនៅក្នុងប្រទេសកម្ពុជា ហើយខ្ញុំសង្ឃឹមថានិន្នាការនេះនឹងបន្តកើនឡើង។ យ៉ាងណាមិញ ការខ្វះខាតសាល និងសម្ភារៈសម្រាប់ហ្វឹកហាត់ក្បាច់គុនយុទ្ធសិល្ប៍ជប៉ុនបានធ្វើឲ្យរាំងស្ទះដល់ដំណើរការហ្វឹកហាត់របស់កីឡាករ កីឡាការិនីវ័យក្មេង។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្លឹបហ្វឹកហាត់ដែលទើបនឹងសាងសង់ថ្មីនេះនឹងជួយសម្រាលបញ្ហាលំបាកទាំងនេះ។ ខ្ញុំកសង្ឃឹមផងដែរថា មជ្ឈមណ្ឌលនេះនឹងរួមចំណែកលើកស្ទួយវិស័យកីឡាក្បាច់គុនយុទ្ធសិល្ប៍ជប៉ុននៅកម្ពុជាបានមួយកម្រិតថែមទៀត។

ខ្ញុំជឿជាក់ថាលោក-អ្នកទាំងអស់គ្នាបានដឹងច្រើនជាងខ្ញុំទៅទៀតថាក្បាច់គុនយុទ្ធសិល្ប៍ជប៉ុនមិនត្រឹមតែមានទស្សនៈលើកស្ទួយភាពមាំមួននៃរាងកាយប៉ុណ្ណោះទេ តែថែមទាំងជួយពង្រឹងស្មារតី និងសីលធម៌ថែមទៀតផង។ ជាក់ស្តែងក្បាច់គុនយុទ្ធសិល្ប៍ទាំងនោះជំរុញនូវគុណធម៌ជាច្រើនដូចជាការចេះដាក់ខ្លួន ការអត់ធ្មត់ និងការគោរពចំពោះអ្នកដទៃ។ ខ្ញុំសង្ឃឹមថា យុវជនកម្ពុជាជាច្រើននឹងអាចពង្រឹងគុណធម៌ទាងនេះតាមរយៈការហ្វឹកហាត់ការ៉ាតេ ក៏ដូចជាក្បាច់គុនយុទ្ធសិល្ប៍ជប៉ុនដទៃទៀត។ សម្រាប់យុវជនដែលត្រៀមរៀបចំផែនការសម្រាប់ពេលអនាគត វាគ្មានអ្វីដែលសំខាន់ជាងភាពរឹងមាំទាំងផ្លូវកាយ និងផ្លូវចិត្តនោះទេ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាមជ្ឈមណ្ឌលហ្វឹកហាត់ក្បាច់គុនយុទ្ធសិល្ប៍ជប៉ុន-កម្ពុជានឹងត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពដោយប្រជាជនកម្ពុជាជាច្រើន។ ខ្ញុំក៏សូមជូនពរចំពោះ លោក ឡាច ច័ន្ទសុវណ្ណ និងខេមរៈសហព័ន្ធការ៉ាតេ-ដូឲ្យសម្រេចនូវរាល់ភារៈកិច្ចផងដែរ។

សូមអរគុណ!!